00787754

E171/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens


ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 09 / 03 / 2012
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA


អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ប្រធាន |
| | ចៅក្រម Claudia FENZ |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **យូរ ឧត្តរា** |
| កាលបរិច្ឆេទ: | ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១២ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

**សេចក្តីសម្រេចលើបណ្តឹងជំទាស់ចំពោះចៅក្រម SILVIA CARTWRIGHT**

**<u>សហព្រះរាជអាជ្ញា</u>**
ជា លាង
Andrew CAYLEY

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**<u>ជនជាប់ចោទ</u>**
នួន ជា
អៀង សារី
ខៀវ សំផន

**<u>មេធាវីជនជាប់ចោទ</u>**
សុន អរុណ
Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW

អាង ឧត្តម

Michael G. KARNAVAS

គង់ សំអុន

Arthur VERCKEN

Jacques VERGÈS

## ១. សេចក្តីផ្តើម

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលបណ្តឹងរបស់ នួន ជា ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ ប្តឹងជំទាស់ចំពោះ និងជាអចិន្ត្រៃយ៍ចំពោះចៅក្រម Silvia Cartwright ពីកិច្ចដំណើរការនីតិវិធីនានាប្រឆាំងនឹង នួន ជា និងស្នើសុំអង្គជំនុំជម្រះសាលាដំបូងជំរុញចៅក្រម Cartwright ឱ្យឈប់ចូលរួមក្នុងកិច្ចដំណើការនីតិវិធី ដោយរង់ចាំសេចក្តីសម្រេចលើបញ្ហានេះ ("បណ្តឹង")។ សហព្រះរាជអាជ្ញាបានដាក់សារណាតបទៅនឹងបណ្តឹងជំទាស់ខាងលើ កាលពីថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២[១]។ ចៅក្រម Cartwright បានសម្រេចមិនអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការដាក់សារណាជាលាយលក្ខណ៍អក្សរទៅអង្គជំនុំជម្រះសាលាដំបូងទាក់ទិននឹងបណ្តឹងនេះ[២]។

## ២. សារណារបស់ភាគី

២. នួន ជា បានធ្វើបណ្តឹងជំទាស់លើចៅក្រម Cartwright និងស្នើសុំដកលោកស្រីចៅក្រម ជាបន្ទាន់ និងជាអចិន្ត្រៃយ៍ដោយសារតែភាពលម្អៀងជាក់ស្តែង ឬបង្ហាញឱ្យឃើញភាពលម្អៀង។ ជាការគាំទ្រដល់បណ្តឹងនេះ នួន ជា បានដកស្រង់ខ្លឹមសារសង្ខេបខាងក្រោមពីរបាយការណ៍មួយដែលបានចុះផ្សាយក្នុងសារព័ត៌មាននូវែលសេឡង់ ("របាយការណ៍ពីសារព័ត៌មាន")៖

> [...] លោកស្រី Cartwright ជាចៅក្រមម្នាក់ក្នុងចំណោមចៅក្រមអន្តរជាតិពីររូបអមជាមួយចៅក្រមកម្ពុជាបីរូបនៅអង្គជំនុំជម្រះសាលាដំបូងដែលកាលពីឆ្នាំ ២០១០ បានសម្រេចឱ្យឌុច មានពិរុទ្ធភាព។
>
> លោកស្រីរស់នៅក្នុងទីក្រុងភ្នំពេញដែលជាទីក្រុងមានអាកាសធាតុក្តៅ សំណើម និងជាទីក្រុងរញ៉េរញ៉ៃពីឆ្នាំ ២០០៨ មកម្ល៉េះ ហើយបានរៀបរាប់ពីបទពិសោធន៍របស់លោកស្រីថា "គួរឱ្យចាប់ចិត្ត ព្រមទាំងមិនសូវសប្បាយក្នុងចិត្តផងដែរ"។

---

១ បណ្តឹងជំទាស់លើកទីបីចំពោះចៅក្រម CARTWRIGHT, លេខឯកសារ E171, ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ ("បណ្តឹងជំទាស់"); ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងជំទាស់លើកទីបីរបស់ នួន ជា ចំពោះចៅក្រម CARTWRIGHT, លេខឯកសារ E171/1, ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ ("ចម្លើយតប")។

២ *មើល* វិធានផ្ទៃក្នុង ៣៧(៧)។

ក្នុងនាមជាមន្ត្រីជាន់ខ្ពស់បំផុតដែលបានតែងតាំងដោយអង្គការសហប្រជាជាតិ លោកស្រី Cartwright យល់ឃើញថា វាជាការទទួលខុសត្រូវរបស់លោកស្រី មិនត្រឹមតែធ្វើឱ្យប្រាកដថា ការជំនុំជម្រះត្រូវតែធ្វើឡើងប្រកបដោយប្រសិទ្ធភាពប៉ុណ្ណោះទេ ប៉ុន្តែស្របពេលជាមួយគ្នា តុលាការក៏ត្រូវបានគ្រប់គ្រងប្រកបដោយភាពស្មោះត្រង់ និងតាមបែបវិជ្ជាជីវៈផងដែរ។ ប៉ុន្តែការណ៍នេះមិនអាចកើតឡើងដោយមិនមានការជំទាស់ ឬគ្មានភាពចម្រូងចម្រាស់នោះឡើយ។

មេធាវីការពារក្ដីបានរិះគន់លោកស្រីជាសាធារណៈកាលពីឆ្នាំមុន បន្ទាប់លោកស្រីបានជួបប្រជុំជាមួយក្រុមសហព្រះរាជអាជ្ញាដែលលោកស្រីបានសារភាពថាបានធ្វើដូចនេះមែន ប៉ុន្តែលោកស្រីនិយាយថា លោកស្រីមានជម្រើសតិចតួច។

*លោកស្រីមានប្រសាសន៍ថា "មេធាវីការពារក្ដីបានផ្ដោតការយកចិត្តទុកដាក់លើការរំខាន ច្រើនជាងការការពារកូនក្ដីរបស់ពួកគេ"។*

*"វាជាយុទ្ធសាស្ត្រធម្មតារបស់មេធាវីការពារក្ដី។ ពាក្យបណ្ដឹងមួយត្រូវបានធ្វើឡើងដោយ ចោទប្រកាន់មកលើរូបខ្ញុំពីចំនួនពីរដង ដោយម្ដងក្នុងនាមខ្ញុំជាសមាជិកនៃអង្គជំនុំជម្រះទាំងមូល និងម្ដងទៀតជារឿងបុគ្គល ហើយក៏មានបណ្ដឹងមួយទៀតចោទប្រកាន់ប្រឆាំងនឹងប្រធានអង្គជំនុំជម្រះដែលជាចៅក្រមកម្ពុជា និងប្រឆាំងនឹងចៅក្រមកម្ពុជាផ្សេងៗទៀតផងដែរ"។*

កាលពីពីរឆ្នាំមុន លោកស្រី Cartwright ត្រូវបានអង្គការសហប្រជាជាតិស្នើឱ្យកោះប្រជុំទៀតទាត់ជាមួយភាគីដទៃទៀតដើម្បីពិភាក្សាអំពីបញ្ហា "អភិបាលកិច្ច"។ លោកស្រីបាននិយាយថា "ពេលខ្លះ ខ្ញុំប្រឆាំងនឹងការប្រជុំនេះដែរ តែក្រោយមកទើបដឹងថាវាជាបញ្ហាសំខាន់ ដូច្នេះ យើងត្រូវជួបប្រជុំគ្នាដើម្បីពិភាក្សាបញ្ហាសំខាន់ៗ ដូចជាថវិកាសម្រាប់តុលាការ បញ្ហាបុគ្គលិក បញ្ហាព័ត៌មានវិទ្យា ជាដើម។ សំខាន់បំផុតនោះគឺបញ្ហាគ្រប់គ្រងសវនាការដែលប៉ះពាល់ដល់ការជំនុំជម្រះ"[៣]។

---

៣ បណ្ដឹង, កថាខណ្ឌ ២ និងជើងទំព័រ ២ ដែលបានដកស្រង់សំដីរបស់ "Michelle Cooke, "Cambodia still reeling from Khmer Rouge", Fairfax NZ News, ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១២" (សេចក្ដីបញ្ជាក់បន្ថែម)។

៣. បណ្តឹងនេះក៏បានធ្វើឡើងដោយផ្អែកលើសេចក្តីថ្លែងនៅក្នុងសាលសវនាការដោយចៅក្រម Cartwright ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង កាលពីថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ ដូចខាងក្រោម ៖

*លោកប្រធាន ៖*

*លោកមេធាវី! យើងបានប្រាប់អម្បាញ់មិញហើយថា សំណុំរឿង ០០៣ និង ០០៤ គឺជាសំណុំរឿងដោយឡែកពីសំណុំរឿង ០០២។ ក្រៅពីនេះ នៅក្នុងសំណុំរឿង ០០២ ទៀតសោត អង្គជំនុំជម្រះបានកំហិតវិសាលភាពនៃការជំនុំជម្រះវគ្គដំបូងដែលយើងកំពុងធ្វើសវនាការនៅពេលនេះ។ យើងគិតថា លោកមេធាវីយល់ច្បាស់អំពីបញ្ហានេះ។ អង្គជំនុំជម្រះសូមរំឭកដល់មេធាវីការពារក្តីឲ្យធ្វើការសួរដេញដោលត្រឹមតែវិសាលភាពដែលពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវធ្វើសវនាការក្នុងសំណុំរឿង០០២/០១ ទៅតាមលំដាប់លេខរៀងពីអង្គហេតុលេខតូចមកលេខធំ។*

*លោក PESTMAN ៖*

*សូមអភ័យទោសលោកប្រធាន! ក្បាលមេក្រូរបស់ខ្ញុំ, ប្រដាប់ស្តាប់របស់ខ្ញុំ ស្តាប់អត់បាន។ ខ្ញុំស្តាប់មិនបានផ្នែកចុងក្រោយទេ។*

*ចៅក្រម CARTWRIGHT ៖*

*ខ្ញុំនឹងជម្រាបលោកជាភាសាអង់គ្លេស ប្រសិនលោកប្រធានអនុញ្ញាត ក្នុងពេលលោកកំពុងរកប្រដាប់ស្តាប់ថ្មី។ លោកប្រធានសម្រេចពីរដងហើយថា លោកមេធាវីគប្បីតាំងសំណួរក្នុងរង្វង់នៃសំណុំរឿង ០០២ វគ្គទីមួយប៉ុណ្ណោះ។ តើលោកយល់ច្បាស់ទេ ប៉ុណ្ណឹង?*

*លោក PESTMAN ៖*

*សំណួររបស់ខ្ញុំ គឺស្ថិតនៅក្នុងរង្វង់ក្នុងវិសាលភាពនៃវគ្គដំបូង –*

*ចៅក្រម CARTWRIGHT ៖*

*សូមលោកកុំតតាំងជាមួយនឹងយើងខ្ញុំ។ សូមលោកបន្តទៅប្រធានបទផ្សេង។ សូមអរគុណ។*

*លោក PESTMAN ៖*

*ខ្ញុំសូមជំទាស់ចំពោះការសម្រេចនេះ។ ខ្ញុំនៅទីនេះដើម្បីបង្ហាញពីការជ្រៀតជ្រែករបស់រដ្ឋាភិបាលក្នុងសំណុំរឿង ០០២ ហើយអាស្រ័យហេតុនេះហើយទើប ខ្ញុំកំពុងសួរសំណួរទាំងនេះ ហើយខ្ញុំគិតថា សំណួរទាំងនេះគឺស្ថិតទាំងស្រុងក្នុងសំណុំរឿងនេះ ពិតណាស់គឺសំណុំរឿង ០០២។ ទោះជាយ៉ាងនេះក្តី ខ្ញុំនឹងសុំសួរសំណួររបស់ខ្ញុំតទៅទៀត។*

*ចៅក្រម CARTWRIGHT ៖*

*ខ្ញុំដឹងហើយ! តួនាទីរបស់លោកនៅទីនេះគឺដើម្បីតំណាង និងការពារកូនក្តីរបស់លោក។ សូមលោកបន្តតាំងសំណួរទាក់ទងនឹងសវនាការនេះ។ សូមអរគុណ*[៤] ។

៤. នួន ជា បានអះអាងថា របាយការណ៍សារព័ត៌មានគឺជាភស្តុតាងដែលបង្ហាញពីភាពលម្អៀងជាក់ស្តែងរបស់ចៅក្រម Cartwright ដែលភស្តុតាងនេះគឺមានលក្ខណៈគ្រប់គ្រាន់ក្នុងការច្រានចោលនូវការសន្មត់ទុកជាមុននូវភាពមិនលម្អៀងរបស់លោកស្រីចៅក្រម[៥]។ នួន ជា ផ្តល់ទឡ្ហីករណ៍ថា យោងតាមយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ("ECtHR"), របាយការណ៍ពីសារព័ត៌មានបង្ហាញពីភាពលម្អៀង ពីព្រោះរបាយការណ៍នេះ បង្ហាញ "អរិភាព ឬបំណងមិនល្អ" ចំពោះ "វិធីសាស្ត្ររបស់មេធាវីការពារក្តីនៅក្នុងរឿងក្តីនេះ"។ របាយកាណ៍ក៏បង្ហាញពី "ទស្សនៈផ្ទាល់ខ្លួន" ដែលប្រឆាំងយ៉ាងមុតមាំទៅនឹងរបៀបដែលមេធាវីការពារក្តី [នួន ជា] បានអនុវត្តកន្លងមក ហើយវាក៏បង្ហាញថា ចៅក្រម Cartwright បាន "រិះគន់ជាសាធារណៈដល់ "ការប្រព្រឹត្តរបស់មេធាវី ការពារក្តីនៅចំពោះមុខតុលាការ" ដែលការណ៍នេះធ្វើឲ្យ នួន ជា មានមូលហេតុក្នុងការជឿថា ចៅក្រម Cartwright ខ្វះភាពអនាគតិ[៦]។

---

៤ ប្រតិចារឹក, ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២, ទំព័រ ៧៥ ដល់ទំព័រ ៧៦។

៥ បណ្តឹង, កថាខណ្ឌ ១៨។

៦ បណ្តឹង, កថាខណ្ឌ ១៨ (ដកស្រង់ពីសំណុំរឿង *Kyprianou ទល់នឹង. Cyprus*, សាលក្រម, ECtHR (7397/01), ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៥, កថាខណ្ឌ ១១៩ ("*Kyprianou*"); *Olujić ទល់នឹង Croatia*, សាលក្រម, ECtHR (លេខឯកសារ 22330/05), ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៩, កថាខណ្ឌ ១១ 11 (*"Olujić"*); *Lavents តទល់នឹង Latvia*, សាលក្រម, ECtHR (លេខឯកសារ 58442/00), ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៣, កថាខណ្ឌ ១១៩ ("*Lavents*"))។

៥. នួន ជា ក៏បានបង្ហាញថា កថាខណ្ឌចំនួនពីរដែលកថាខណ្ឌនីមួយៗ ឬកថាខណ្ឌទាំងពីររួមគ្នានៃរបាយការណ៍ពីសារព័ត៌មាននេះ មានភាពគ្រប់គ្រាន់ក្នុងការបង្ហាញអង្គហេតុមួយនៃភាពលម្អៀងប្រឆាំងនឹងចៅក្រម Cartwright ពីព្រោះកថាខណ្ឌទាំងនេះបង្ហាញថា លោកស្រីមានទស្សនៈមិនពេញចិត្តចំពោះរឿងក្តីរបស់ នួន ជា[៧]។

៦. ក្រៅពីនេះ នួន ជា បានអះអាងបន្ថែមទៀតថា នៅពេលពិនិត្យរបាយការណ៍សារព័ត៌មានរួមជាមួយនឹងសេចក្តីថ្លែងរបស់លោកស្រីចៅក្រមនៅក្នុងអំឡុងពេលសវនាការ កាលពីថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ នោះបង្ហាញថា ចៅក្រម Cartwright ប្រកាន់ជំហរថា ៖ (i) ការជំទាស់តវ៉ារបស់មេធាវីការពារក្តី [ចំពោះឯករាជ្យភាពរបស់តុលាការ] គឺពុំមានមូលដ្ឋានផ្លូវច្បាប់ និង/ឬឥតប្រយោជន៍, (ii) ពុំមានការជ្រៀតជ្រែកដែលធ្វើឱ្យប៉ះពាល់ហួសហេតុដល់សំណុំរឿង ០០២ ពីសំណាក់រដ្ឋាភិបាលមកលើ អ.វ.ត.ក ទេ និង/ឬ (iii) ចៅក្រមទាំងអស់នៃតុលាការនេះមិនបានទទួលរងសម្ពាធនយោបាយពីខាងក្រៅឡើយ”[៨]។ ដោយសារតែការប្រកាន់យកគោលជំហរបែបនេះហើយ ទើបចៅក្រម Cartwright ត្រូវបានចោទប្រកាន់ថាបានទប់ស្កាត់ជាមុននូវការលើកឡើងបន្ថែមទៀតលើបញ្ហាដូចខាងលើនេះ និងបានបង្ហាញឱ្យឃើញពីភាពលម្អៀង។

៧. ម្យ៉ាងវិញទៀត នួន ជា លើកឡើងថា ភស្តុតាងទាំងអស់ដែលបានបង្ហាញឱ្យឃើញថាមានភាពលម្អៀងដូចដែលបានរៀបរាប់នៅក្នុងពាក្យបណ្តឹង អាចនាំឱ្យអ្នកសង្កេតការណ៍ប្រកបដោយវិចារណញ្ញាណដែលបានទទួលព័ត៌មានគ្រប់គ្រាន់ យល់ដឹងសមស្របអំពីការខ្វះភាពអនាគតិរបស់ចៅក្រម Cartwright[៩]។

៨. នួន ជា បញ្ជាក់បន្ថែមថា ចៅក្រម Cartwright មិនគប្បី “ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ” ឬបង្ហាញជាសាធារណៈនូវ “គោលជំហរណាមួយដែលមិនស្របទៅនឹង “ការទាមទារដ៏ខ្ពស់នៃយុត្តិធម៌” និងលក្ខណៈដ៏ខ្ពស់ [...] នៃមុខងារផ្នែកតុលាការ” និងថា ដោយសារតែមានគោលជំហរដូចនេះហើយទើប ចៅក្រម Cartwright “ត្រូវតែបានដកចេញពីដំណើរការសវនាការ

---

[៧] បណ្តឹង, កថាខណ្ឌ ១៩ (ដកស្រង់ពី *Buscemi ទល់នឹង អ៊ីតាលី*, សាលក្រម, ECtHR (លេខឯកសារលេខ 29569/95), ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៩៩, កថាខណ្ឌ ៦៨ (“*Buscemi*”))។

[៨] បណ្តឹង, កថាខណ្ឌ ២០។

[៩] បណ្តឹង, កថាខណ្ឌ ២២។

នៅពេលនេះ"[១០]។ នួន ជា បានស្នើបន្ថែមទៀតថា ចៅក្រម Cartwright មានកាតព្វកិច្ចត្រូវគោរពតាមមាត្រា ៥៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ក្នុងការឈប់ចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ដោយរង់ចាំសេចក្តីសម្រេចលើបណ្តឹងនេះ ឬជាជម្រើសម្យ៉ាងទៀត លោកស្រីគួរតែលាឈប់ពីមុខតំណែង ស្របតាមវិធាន ៣៤(៥) នៃវិធានផ្ទៃក្នុង[១១]។

៩. ជាការឆ្លើយតប សហព្រះរាជអាជ្ញាបានលើកអំណះអំណាងថា សេចក្តីថ្លែងការណ៍ព័ត៌មានដែលធ្វើឡើងដោយចៅក្រមក្នុងមុខដំណែង ឬការធ្វើអត្ថាធិប្បាយផ្សេងៗដែលធ្វើឡើងក្នុងពេលនៃកិច្ចដំណើរការនីតិវិធីមិននាំឱ្យមានការសន្និដ្ឋានអំពីភាពលម្អៀង ដែលខ្លួនមានសិទ្ធិធ្វើឡើងនោះទេ លើកលែងតែសេចក្តីថ្លែងការណ៍ទាំងនោះ "មានលក្ខណៈជាក់លាក់ និងជាលក្ខណៈបុគ្គលប្រឆាំងនឹងជនជាប់ចោទ" "ជាពិសេស ដុតរោល ឬជេរប្រមាថ" ឬ "ឈានទៅដល់ការធ្វើបុរេវិនិច្ឆ័យទៅលើបញ្ហានានាដែលជាស្នូលនៃពិរុទ្ធភាពរបស់ជនជាប់ចោទ ឬទៅលើលទ្ធផលនៃរឿងក្តី"[១២]។ ការវាយតម្លៃអំពីភាពលម្អៀងជាក់ស្តែងតាមរយៈការធ្វើសេចក្តីថ្លែងតាមសារព័ត៌មានគឺត្រូវថ្លឹងថ្លែងដោយឈរលើ "បរិបទជាក់លាក់ និងដោយតឹងរ៉ឹង"[១៣]។

១០. សហព្រះរាជអាជ្ញាធ្វើការអះអាងបន្ថែមទៀតថា ការធ្វើអត្ថាធិប្បាយរបស់ចៅក្រម Cartwright នៅក្នុងរបាយការណ៍តាមសារព័ត៌មាន គឺជាសេចក្តីសង្កេតជាទូទៅ ដោយមិនសំដៅប្រឆាំងនឹង នួន ជា ឬក្រុមមេធាវីការពារក្តី នួន ជា និងក៏មិននាំឱ្យមានលទ្ធផលបុរេវិនិច្ឆ័យលើបញ្ហានានា ឬបញ្ហាផ្លូវច្បាប់ ក៏ដូចជាសំណើសុំប្តឹងជំទាស់ចិត្តនោះដែរ[១៤]។ ទោះបីជា សេចក្តីអធិប្បាយបង្ហាញពីទស្សនៈមិនពេញចិត្តចំពោះករណីរបស់ នួន ជា ដូចការលើកឡើងរបស់មេធាវីការពារក្តីក៏ដោយ ក៏"ទស្សនៈមិនពេញចិត្ត" នេះមានលក្ខណៈមិនគ្រប់គ្រាន់ក្នុងការបង្ហាញអង្គហេតុនៃភាពលម្អៀងជាក់ស្តែងឡើយ[១៥]។ ភស្តុតាងដែលបានបង្ហាញដោយ នួន ជា ដើម្បីគាំទ្រដល់បណ្តឹងនេះ មិនបានបង្ហាញឱ្យឃើញពីមូលដ្ឋានណាមួយដើម្បីឱ្យអ្នកសង្កេតការណ៍ប្រកបដោយវិចារណញ្ញាណមាន

---

[១០] បណ្តឹង, កថាខណ្ឌ ២៣ (ដកស្រង់ពី *Buscemi*, កថាខណ្ឌ ៦៧)។

[១១] បណ្តឹង, កថាខណ្ឌ ១៧។

[១២] ចម្លើយតប កថាខណ្ឌ ៦ ដល់ ១១ (ដកស្រង់ពី *Olujić*, *Lavents* និង *Kyprianou*)។

[១៣] ចម្លើយតប កថាខណ្ឌ ១១។

[១៤] ចម្លើយតប កថាខណ្ឌ ១៣។

[១៥] ចម្លើយតប កថាខណ្ឌ ១៤។



95 / ME

ការបារម្ភថា លោកស្រីចៅក្រម Cartwright មានទស្សនៈមិនពេញចិត្តចំពោះបញ្ហានានាដែលជាស្នូលដល់រឿងក្តីរបស់ នួន ជា ទេ[១៦]។ ជាចុងក្រោយ សហព្រះរាជអាជ្ញាស្នើដល់អង្គជំនុំជម្រះឱ្យច្រានចោលបណ្តឹងនេះ[១៧]។

## ៣. សំអាងហេតុ

### ៣.១ ក្របខ័ណ្ឌគតិយុត្ត

១១. វិធាន ៣៤ នៃវិធានផ្ទៃក្នុង ចែងអំពីបណ្តឹងជំទាស់ចំពោះចៅក្រម។ វិធាន ៣៤(២) នៃវិធានផ្ទៃក្នុង ចែងថា ៖

> ភាគីអាចធ្វើបណ្តឹងជំទាស់ចំពោះចៅក្រម ក្នុងករណីណាមួយដែលចៅក្រមរូបនោះមាន ឬធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុ ឬមានការពាក់ព័ន្ធដែលអាចធ្វើឱ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬអាចបង្កើតឱ្យមានភាពលម្អៀង។

១២. ការស្តែងឱ្យឃើញនូវភាពលម្អៀងអាចកើតមាន ប្រសិនបើ "ចៅក្រមមួយរូបគឺជាភាគីក្នុងរឿងក្តី ឬមានប្រយោជន៍ហិរញ្ញវត្ថុ ឬផលប្រយោជន៍ផ្ទាល់ខ្លួនដែលកើតចេញពីលទ្ធផលនៃរឿងក្តី ឬប្រសិនបើសេចក្តីសម្រេចរបស់ចៅក្រមរូបនោះនឹងឈានទៅរកការលើកស្ទួយបុព្វហេតុមួយដែលគាត់មានចំណែកក្នុងនោះ ឬកាលៈទេសៈមួយចំនួនអាចនាំឱ្យអ្នកសង្កេតការណ៍ប្រកបដោយវិចារណញ្ញាណម្នាក់ដែលទទួលបានព័ត៌មានគ្រប់គ្រាន់ ឈ្មេយល់បានថាមានភាពលម្អៀង"[18]។ ដូចការកត់សម្គាល់ជាប្រចាំរបស់អង្គជំនុំជម្រះសាលាដំបូង អ្នកសង្កេតការណ៍ប្រកបដោយវិចារណញ្ញាណនៅក្នុងន័យនេះគឺជា "មនុស្សម្នាក់ដែលទទួលបានព័ត៌មានគ្រប់គ្រាន់ មានការយល់ដឹងរាល់កាលៈទេសៈដែលពាក់ព័ន្ធ រួមទាំងប្រពៃណីនៃសុចរិតភាព និងអនាគតិដែលបង្កើតបានជាផ្នែកមួយនៃសាវតារ និងបានយល់ដឹងអំពីការពិតដែលថា អនាគតិគឺជាករណីកិច្ចមួយក្នុង

---

[១៦] ចម្លើយតប កថាខណ្ឌ ២២។

[១៧] ចម្លើយតប កថាខណ្ឌ ២៣។

[១៨] សេចក្តីសម្រេចលើបណ្តឹងជំទាស់ចំពោះចៅក្រម Silvia CARTWRIGHT, លេខឯកសារ E137/5, ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១១, កថាខណ្ឌ ១៣ (ដកស្រង់ពី *រដ្ឋអាជ្ញា ទល់នឹង Furundžija*, សាលក្រម, អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (IT-95-17/1-A), ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០ ("សាលដីកាលើបណ្តឹងសាទុក្ខចំពោះរឿងក្តី *Furundžija*"), កថាខណ្ឌ ១៨៩។

00787763



ចំណោមករណីកិច្ចដទៃទៀតដែលចៅក្រមត្រូវប្រកាន់ខ្ជាប់”[19]។ ហេតុដូចនេះ ចំណុចចាប់ផ្ដើមនៃការកំណត់អំពីភាពលម្អៀងរបស់ចៅក្រម គឺការសន្មត់អំពីភាពមិនលម្អៀងដែលមានចំពោះចៅក្រម អ.វ.ត.ក ផ្អែកលើការធ្វើសច្ចាប្រណិធានចូលកាន់តំណែង និងលក្ខណៈសម្បត្តិសម្រាប់ការតែងតាំងពួកគាត់ជាចៅក្រម[២០]។ ភាគីប្ដឹងជំទាស់ត្រូវតែបង្ហាញរាល់ភស្តុតាងដែលខ្លួនយកមកធ្វើជាសំអាង នៅពេលខ្លួនដាក់បណ្ដឹងជំទាស់[២១]។

១៣. វិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង តម្រូវថា ភាគីដែលធ្វើបណ្ដឹងជំទាស់ “ត្រូវបង្ហាញឱ្យច្បាស់លាស់អំពីមូលហេតុនៃបណ្ដឹង និងត្រូវមានភស្តុតាងគាំទ្រ” ផងដែរនៅក្នុងពាក្យសុំប្ដឹងជំទាស់ចំពោះចៅក្រមណាម្នាក់។ បណ្ដឹងដែលមានភាពស្មានៗ ឬផ្អែកលើ “ការយល់ឃើញ ឬការសង្ស័យថាមានលម្អៀងប៉ុណ្ណោះ” ពីសំណាក់ជនជាប់ចោទណាមួយនោះ គឺមិនគ្រប់គ្រាន់ឡើយ[២២]។

១៤. តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប បានសម្រេចថា ការបញ្ចេញមតិរបស់ចៅក្រមដល់ប្រព័ន្ធព័ត៌មានដែលមានន័យដោយប្រយោលថា គាត់មានទស្សនៈមិនពេញចិត្តជាមុនចំពោះរឿងក្ដីរបស់អ្នកដាក់ពាក្យសុំ ឬប្រកាន់ខ្ជាប់នូវគោលជំហរមួយពិតប្រាកដលើលទ្ធផលនៃរឿងក្ដីរបស់អ្នកដាក់ពាក្យសុំ

[១៩] លេខឯកសារ E137/5, កថាខណ្ឌ ១៤ (ដកស្រង់ពីសាលដីកាលើបណ្ដឹងសាទុក្ខចំពោះរឿងក្ដី *Furundžija* , កថាខណ្ឌ ១៩០)។

[20] សេចក្ដីសម្រេចលើបណ្ដឹងរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្ដឹងជំទាស់ចំពោះលោកចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី, លេខឯកសារ E55/4, ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១១, កថាខណ្ឌ ១២, លេខឯកសារ E137/5, កថាខណ្ឌ ១៤; សេចក្ដីសម្រេចស្ដីពីបណ្ដឹងជំទាស់ជាបន្ទាន់របស់សហមេធាវីជនជាប់ចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល ដែលកំពុងរង់ចាំបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ក្នុងសំណុំរឿងរបស់ នួន ជា, លេខឯកសារ C11/29, ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៨, កថាខណ្ឌ ១៥ ដល់ ១៧ (ដកស្រង់ពីសាលដីកាលើបណ្ដឹងសាទុក្ខចំពោះរឿងក្ដី *Furundžija* , កថាខណ្ឌ ១៩៦)។

[២១] លេខឯកសារ E137/5, កថាខណ្ឌ ១៤, *មើលផងដែរ* សាលដីកាលើបណ្ដឹងសាទុក្ខចំពោះរឿងក្ដី *Furundžija* , កថាខណ្ឌ ១៩៧) (ដោយធ្វើការកត់សម្គាល់ថា ចៅក្រមអាចពិតអាច “កែប្រែចិត្តរបស់ខ្លួនចំពោះជំនឿ ឬភាពអគតិផ្ទាល់ខ្លួនដែលមិនពាក់ព័ន្ធ”)។

[២២] លេខឯកសារ E137/5, កថាខណ្ឌ ១៤ (ដកស្រង់ពី*រដ្ឋអាជ្ញា តទល់នឹង Karemera et al.*, សេចក្ដីសម្រេចលើបណ្ដឹងជំទាស់របស់ Joseph Nzirorera ចំពោះចៅក្រម Byron និងការសុំផ្អាកកិច្ចដំណើរការនីតិវិធី, អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ៉្វាន់ដា (ICTR-98-44-T), ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩ កថាខណ្ឌ ៥)។

គឺជាការរំលោភលើសិទ្ធិរបស់អ្នកដាក់ពាក្យសុំនោះ ក្នុងការទទួលបានសវនាការដោយយុត្តិធម៌ អនុលោមតាមមាត្រា ៦ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (“ECHR”)[២៣]។ ទោះជាយ៉ាងនេះក្តី ការបញ្ចេញយោបល់របស់ចៅក្រមនៅក្នុងប្រព័ន្ធសារព័ត៌មានមិនបង្ហាញពីការខ្វះភាពអនាគតិ ឬ នាំដល់ការរំលោភដល់សិទ្ធិទទួលបានសវនាការប្រកបដោយយុត្តិធម៌របស់អ្នកដាក់ពាក្យសុំ បើទោះបីជាថាចៅក្រម “មិនគប្បីប្រើប្រាស់ប្រព័ន្ធសារព័ត៌មានដើម្បីបញ្ចេញនូវទស្សនៈរបស់ខ្លួនក៏ដោយ ”[២៤]។

១៥. ផ្ទុយទៅនឹងការអះអាងរបស់មេធាវីការពារក្តី នួន ជា វិធានផ្ទៃក្នុងច្រាប់បញ្ចូលនីតិវិធីនានា ដែលអនុវត្តនៅក្នុងកិច្ចដំណើរការនីតិនៅចំពោះមុខ អ.វ.ត.ក ហេតុដូចនេះ វិធាននេះគឺជាមានលក្ខណៈពិសេស (*lex specialis*)[២៥]។ អាស្រ័យហេតុនេះ កិច្ចដំណើរការនីតិវិធីបច្ចុប្បន្នត្រូវបានគ្រប់គ្រងដោយវិធានផ្ទៃក្នុង មិនមែនដោយបទប្បញ្ញត្តិពាក់ព័ន្ធនានានៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឡើយ។ វិធាន ៣៤(៦) នៃវិធានផ្ទៃក្នុង ការពារសិទ្ធិរបស់អ្នកដាក់ពាក្យសុំក្នុងការទទួលបានសវនាការប្រកបដោយយុត្តិធម៌ ដោយតម្រូវឱ្យធ្វើការជំនួសចៅក្រមដែលជាកម្មវត្ថុនៃពាក្យបណ្តឹងជំទាស់ដោយចៅក្រមបម្រុង “សម្រាប់តែគោលបំណងនៃបណ្តឹងជំទាស់ប៉ុណ្ណោះ”។ វិធាន ៣៤(៥) ចែងបន្ថែមទៀតថា ចៅក្រមដែលត្រូវបានប្តឹងជំទាស់ “អាចបន្តចូលរួមក្នុងកិច្ចដំណើរការនីតិវិធីដោយរង់ចាំសេចក្តីសម្រេច” ឬជាជម្រើសម្យ៉ាងទៀត “អាចសម្រេចលាលែង

---

[២៣] *Buscemi*, កថាខណ្ឌ ៦៨; *Olujić*, កថាខណ្ឌ ៦៥; *Lavents*, កថាខណ្ឌ ១១៩។ កំណត់សម្គាល់ដែលពាក់ព័ន្ធទៅនឹងបំពារបំពានមាត្រា ៦ មានជាអាទិ៍ ការផ្តល់មតិយោបល់លើអង្គសេចក្តី ឬលទ្ធផលនៃករណីរបស់អ្នកដាក់ពាក្យសុំ (*Buscemi*, កថាខណ្ឌ ៤០; *Olujić*, កថាខណ្ឌ ២១ និង ៦៤; *Lavents*, កថាខណ្ឌ ១១៩), ការបង្ហាញពីជម្លោះផលប្រយោជន៍ជាក់លាក់មួយ (*Olujić*, កថាខណ្ឌ ៦២ ដល់ ៦៣) និងធ្វើឱ្យប៉ះពាល់ ឬវាយប្រហារលើចរិតលក្ខណៈរបស់អ្នកដាក់ពាក្យសុំ (*Olujić*, កថាខណ្ឌ ២២ និង ៦៦); *មើលផងដែរ Previti តទល់នឹង អ៊ីតាលី*, សេចក្តីសម្រេចអំពីភាពអាចទទួលយកបាន, ECtHR (លេខឯកសារ 45291/06), ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៩, កថាខណ្ឌ ២៦៥។

[២៤] *Buscemi*, កថាខណ្ឌ ៦៧។

[២៥] សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ នួន ជា ពាក់ព័ន្ធនឹងការចោទប្រកាន់ពីចរិតលក្ខណៈផ្ទុយគ្នានៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ទៅលើច្បាប់រដ្ឋធម្មនុញ្ញ, លេខឯកសារ E51/14, ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១១។

ដោយស្ម័គ្រចិត្ត”។ អនុលោមតាមសិទ្ធិដែលបានចែងនៅក្នុងអនុវិធាននេះ លោកស្រីចៅក្រមបានជ្រើសរើសបន្តចូលរួមក្នុងកិច្ចដំណើរការនីតិវិធីតុលាការ[២៦]។

## ៣.២ ការវិភាគ

១៦. អង្គជំនុំជម្រះបានពិនិត្យខ្លឹមសារនៃរបាយការណ៍តាមសារព័ត៌មាន និងសេចក្តីថ្លែងក្នុងសាលសវនាការដើម្បីកំណត់ថា តើព័ត៌មានទាំងនេះឆ្លើយតបទៅនឹងលក្ខខណ្ឌកម្រិតខ្ពស់ដែលចាំបាច់ក្នុងការបដិសេធនូវការសន្មត់ជាមុនអំពីភាពគ្មានលម្អៀងរបស់ចៅក្រម Cartwright ដែរ ឬយ៉ាងណា។

១៧. អង្គជំនុំជម្រះយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាដែលថា របាយការណ៍តាមសារព័ត៌មាននេះមិនបានលើកយោងអ្វីមួយចំពោះ នួន ជា ឬចំពោះមេធាវីការពារក្តី នួន ជា ទេ[២៧]។ ក្រុមមេធាវីការពារក្តី នួន ជា គ្រាន់តែអះអាងថា “ការណ៍នេះត្រូវតែបានសន្មត់ថា ការលើកឡើងរបស់ចៅក្រម Cartwright គឺត្រូវបានធ្វើឡើងចំពោះក្រុមមេធាវីការពារក្តី នួន ជា”[២៨]។ ប៉ុន្តែផ្ទុយទៅវិញ អង្គជំនុំជម្រះយល់ថា ការកត់សម្គាល់ទាំងនេះសំដៅដល់យុទ្ធសាស្ត្រសំខាន់ៗដែលជាធម្មតាត្រូវបានប្រើប្រាស់ដោយមេធាវីការពារក្តី មិនមែនសំដៅដល់ករណីរបស់ជនជាប់ចោទណាម្នាក់ឡើយ ហើយរិតតែមិនប៉ះពាល់ទៅលើលទ្ធផលនៃការជំនុំជម្រះ។ គ្មានការកត់សម្គាល់ណាមួយក្នុងចំណោមការកត់សម្គាល់ដែលបានដកស្រង់នៅក្នុងរបាយការណ៍តាមព័ត៌មានបង្ហាញថា ចៅក្រម Cartwright មានទស្សនៈមិនពេញចិត្តចំពោះ នួន ជា ឬធ្វើការវាយតម្លៃអវិជ្ជមានលើរឿងក្តីរបស់ នួន ជា ឬមានទស្សនៈមិនពេញចិត្តចំពោះជនជាប់ចោទណាផ្សេងទៀតឡើយ។

---

២៦ សេចក្តីសម្រេចលើសំណើរបស់ជនត្រូវចោទ អៀង សារី សុំឱ្យមានវិធានការ សមរម្យពាក់ពន្ធ័នឹងសេចក្តីថ្លែងការណ៍មួយចំនួនដែលធ្វើដោយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលតតាំងនឹងឯករាជ្យភាពរបស់ចៅក្រមអង្គបុរេជំនុំជម្រះ Katinka LAHUIS និង Rowan DOWNING, ០០២/២០-១០-២០០៩-អវតក/កសចស (អបជ-០៣), លេខឯកសារ ៥, ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩, កថាខណ្ឌ ៣ និង ១៥។

២៧ ចម្លើយតប កថាខណ្ឌ ១២។

២៨ បណ្តឹង, កថាខណ្ឌ ២។

១៨. ទាក់ទងទៅនឹងសេចក្តីថ្លែងការណ៍ក្នុងសវនាការរបស់ចៅក្រម Cartwright អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ទាំងនេះគឺជាយោបល់នានាក្នុងការបដិសេធមេធាវីការពារក្តីដែលបានច្រានចោលម្តងហើយម្តងទៀតនូវការណែនាំមុនៗរបស់លោកប្រធានអង្គជំនុំជម្រះ[២៩]។ អង្គជំនុំជម្រះយល់ឃើញថា សេចក្តីថ្លែងការណ៍ទាំងនេះ គឺជាការអនុវត្តសមស្របនូវឆន្ទានុសិទ្ធិរបស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូងដើម្បីធានាឱ្យមានកិច្ចដំណើរការនីតិវិធីត្រឹមត្រូវ។ ត្រឹមតែសេចក្តីសម្រេចបដិសេធរបស់ចៅក្រមទៅលើភាគីណាមួយនៃរឿងក្តីមិនអាចឱ្យអ្នកសង្កេតការណ៍ប្រកបដោយវិចារណញ្ញាណ កំណត់ថាមានភាពលម្អៀងនោះទេ[៣០] ពោលគឺគ្រាន់តែការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ចៅក្រមក្នុងការគ្រប់គ្រងកិច្ចដំណើរការនីតិវិធីមិនអាចសន្និដ្ឋានថាចៅក្រមនោះមានភាពលំអៀងបានឡើយ។ នៅពេលមេធាវីការពារក្តី បានច្រានចោលការសម្រេចដោយផ្ទាល់មាត់ នោះ ដំណោះស្រាយត្រឹមត្រូវនោះ គឺ បណ្តឹងសារទុក្ខ មិនមែនប្តឹងដកហូតសិទ្ធិចៅក្រមទេដោយ មូលហេតុថា ចៅក្រមទាំងអស់អាចនឹងប្រឈមនឹងការប្តឹងដកសិទ្ធិធ្វើជាចៅក្រម នៅពេលណាចៅក្រមទាំងនោះធ្វើសេចក្តីសម្រេចអវិជ្ជមានប្រឆាំងនឹងភាគី។

១៩. ផ្ទុយទៅនឹងការជូនសំអាងរបស់មេធាវីការពារក្តី នួន ជា គ្មានការសម្រេចដោយផ្ទាល់មាត់ ឬរបាយការណ៍តាមសារព័ត៌មាន នៅពេលពិចារណាដោយឡែកពីគ្នា ឬពិចារណារួមគ្នា ដែលបង្ហាញពីការចោទប្រកាន់ថាមានភាពលម្អៀងឡើយ។ ដោយសារតែ គ្មានសេចក្តីថ្លែងការណ៍ណាមួយនៃសេចក្តីថ្លែងការណ៍នានារបស់ចៅក្រម Cartwright បង្ហាញពីភាពលម្អៀងនោះ សំណើដែលថា លោកស្រីបានបញ្ចេញ "គោលជំហរជាសាធារណៈដែលមិនស្របទៅនឹង 'ការទាមទារដ៏ខ្ពស់នៃយុត្តិធម៌ និងលក្ខណៈដ៏ខ្ពស់នៃ [...] មុខងារតុលាការ'" ពុំមានមូលដ្ឋានឡើយ[៣១]។

២០. បន្ទាប់ពីបានពិនិត្យលើព័ត៌មានទាំងមូលដែលបានលើកឡើងនៅក្នុងបណ្តឹង អង្គជំនុំជម្រះសន្និដ្ឋានថា ព័ត៌មានទាំងនេះពុំមានភាពគ្រប់គ្រាន់ក្នុងការដកចេញនូវការសន្និដ្ឋានអំពីភាពអនាគតិរបស់

---

[២៩] ប្រតិចារិក, ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២, ទំព័រ ៧៤ ដល់ ៧៥។

[៣០] សេចក្តីសម្រេចលើបណ្តឹងរបស់ ខៀវ សំផន ដែលប្តឹងជំទាស់ចំពោះសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Marcel LEMONDE សំណុំរឿង ០០២/ ១៣ តុលា ២០០៩/អវតក/អបជ ឯកសារលេខ ០៧ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ កថាខណ្ឌ ៣៥។

[៣១] បណ្តឹង, កថាខណ្ឌ ២៣។

ចៅក្រម Cartwright នោះទេ។ អាស្រ័យហេតុនេះ បណ្តឹងនេះត្រូវបានបដិសេធចោល ដោយសារវាគ្មានមូលដ្ឋាន។

**យោងតាមហេតុផលដែលបានបញ្ជាក់ខាងលើ អង្គជំនុំជម្រះសាលាដំបូង សម្រេច ÷**

**បដិសេធ** បណ្តឹងរបស់ នួន ជា ក្នុងការប្តឹងជំទាស់ចិត្តជាបន្ទាន់ និងជាអចិន្ត្រៃយ៍ចំពោះចៅក្រម Cartwright។

ភ្នំពេញ, ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១២
ប្រធានអង្គជំនុំជម្រះសាលាដំបូង

និល ណុន